# សាធារណរដ្ឋប្រជាមានិតកម្ពុជា

## ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ទីស្តីការរដ្ឋមន្រ្តីក្រសួងយុត្តិធម៌

លេខ ០៣ រប-១០១៦-៨៤

ភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៨៤

# សារាចរណែនាំ

# រដ្ឋមន្រ្តីក្រសួងយុត្តិធម៌

**ជម្រាបមក**

-សមមិត្តប្រធាន អនុប្រធាន ចៅក្រមនៃតុលាការប្រជាជនខេត្ត-ក្រុង

-សមមិត្តរដ្ឋអាជ្ញា រដ្ឋអាជ្ញារងអមតុលាការប្រជាជនខេត្ត-ក្រុង

**កម្មវត្ថុ** ការប្រើប្រាស់ត្រារបស់តុលាការ និងរបស់អយ្យការ ។

ក្រសួងយុត្តិធម៌សូមជម្រាបថា ដើម្បីអោយការងារតុលាការ និងអយ្យការ ប្រព្រឹត្តទៅបានជោគជ័យ និងប្រសិទ្ធិភាព ក្រុមប្រឹក្សារដ្ឋមន្រ្តីបានកំណត់អោយតុលាការប្រជាជន ខេត្ត-ក្រុង និងអយ្យការអមតុលាការប្រជាជន ខេត្ត-ក្រុង មានសិទ្ធិប្រើប្រាស់ត្រាសម្រាប់ប្រថាប់លើលិខិតជាផ្លូវការផ្សេងៗ របស់ខ្លួន ។

-ដើម្បីអោយការប្រើប្រាស់ត្រាអនុវត្តទៅបានត្រឹមត្រូវក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចតទៅៈ

ក-សមមិត្ត ប្រធានតុលាការ ត្រូវប្រើត្រាសម្រាប់បោះលើលិខិតទាំងអស់ដែលខ្លួនចុះហត្ថលេខា ទោះជាលិខិតការងារផ្នែករដ្ឋបាលក្តី ឬ ការងារផ្នែកបច្ចេកទេសក្តី ដូចជាលិខិតដីកាបញ្ជូនរបាយការណ៍ ដីកាកោះ ដីកាអញ្ជើញ សាលក្រម ឬ សេចក្តីសម្រេចផ្សេងៗ របស់តុលាការ ។

ខ-សមមិត្ត ប្រធានតុលាការ អាចប្រគល់សិទ្ធិអោយសមមិត្តអនុប្រធានចុះហត្ថលេខា និងប្រថាប់ត្រាលើលិខិតខ្លះដែលមិនចាំបាច់សមមិត្តប្រធានចុះហត្ថលេខា ។ ក្នុងករណីនេះសមមិត្តអនុប្រធានសរសេរៈ

ជ-ប្រធានតុលាការ និង ត.ប

អនុប្រធានតុលាការ

មុនចុះហត្ថលេខា ។ ត.ប មានន័យថា តាមបញ្ជា ឬ តាមបង្គាប់ ។

គ-ក្នុងករណី ដែលប្រធានអវត្តមានហើយដែលការងារត្រូវសម្រេចជាបន្ទាន់មិនអាចរង់ចង់បាននោះសមមិត្តអនុប្រធានតុលាការអាចចុះហត្ថលេខា និងប្រថាប់ត្រាជំនួសសមមិត្តប្រធាន ។

ឃ-ក្នុងករណីអវត្តមានរយៈពេលយូរ ដោយត្រូវបំពេញភារកិច្ច បំពេញបេសកកម្ម ក្រៅខេត្ត ឬ ក្រៅប្រទេស នោះសមមិត្តប្រធាន ធ្វើលិខិតប្រគល់សិទ្ធិអោយសមមិត្តអនុប្រធានដំណើរការការងារជំនួសខ្លួនបានន័យថាសិទ្ធិចុះហត្ថលេខា នឹង ប្រថាប់ត្រាលើលិខិតដែលបានចុះហត្ថលេខា ។

ង-សមមិត្តរដ្ឋអជ្ញា រដ្ឋអាជ្ញារង មានសិទ្ធិប្រើត្រាប្រថាប់លើលិខិតផ្សេងៗ របស់អយ្យកា មានលក្ខណៈដូចគ្នានឹងសិទ្ធិរបស់ប្រធាន អនុប្រធានតុលាការ ដែលមានចែងក្នុងចំណុច ក-ខ-ង-និង ឃ ។

ច-ក្នុងពេលបើកសវនាការ ចៅក្រមដែលត្រូវបានចាត់តាំងអោយធ្វើជា ប្រធានសវនាការណាមួយ ក៏ត្រូវមានសិទ្ធិប្រើប្រាស់ត្រាសម្រាប់ប្រថាំត្រាលើលិខិតទាំងឡាយដែលទាក់ទងនឹងសវនាការនោះដែរ ។

ឆ-ក្នុងពេលប្រធាន និងអនុប្រធានតុលាការអវត្តមាន ហើយការងារត្រូវសម្រេចជាបន្ទាន់មិនអាចរង់ចាំបាន នោះចៅក្រមអាចដំណើរការការងារជំនួសប្រធានតុលាការ ដោយចុះហត្ថលេខា និងប្រថាប់ត្រាលើលិខិតជាផ្លូវការផ្សេងៗ

ជ-ក្នុងការថែរក្សាត្រា សមមិត្តប្រធាន អនុប្រធានតុលាការ សមមិត្តរដ្ឋអាជ្ញា រដ្ឋអាជ្ញារង ជាអ្នកទទួលខុសត្រូវផ្ទាល់ ។ ចៀសវាងដាច់ខាតប្រើត្រាមិនត្រឹមត្រូវឬប្រើក្នុងការមិនចាំបាច់ឬបណ្តោយអោយត្រានេះធ្លាក់ទៅលើដៃអ្នកដែលមិនស្មោះត្រង់ បម្រើប្រយោជន៍ផ្ទាល់ខ្លួន ឬបម្រើឧបាយកលរបស់ខ្មាំងសត្រូវយកត្រានោះទៅវាយលើឯកសារដែលបានចុះហត្ថលេខាក្លែងបន្លំជំនួសអ្នកពេញសិទ្ធិ ។

ឈ-តុលាការអយ្យការខេត្ត-ក្រុង ដែលបានទទួលត្រាពីថ្នាក់លើ ត្រូវប្រើត្រាអោយត្រូវតាមភារកិច្ចដែលថ្នាក់លើប្រគល់អោយមិនត្រូវយកត្រានេះទៅប្រើក្រៅផ្លូវច្បាប់ឡើយ ។

-ក្រសួងយុត្តិធម៌សង្ឃឹមទុកចិត្តថា សមមិត្តប្រធាន អនុប្រធានតុលាការ ចៅក្រមសមមិត្តរដ្ឋរាជ្ញា រដ្ឋអាជ្ញារង និងយកចិត្តទុកដាក់គ្រប់គ្រងថែរក្សា និងប្រើត្រានេះអោយបានសមស្របតាមគោលមាគ៌ានយោបាយរបស់បក្ស និងច្បាប់របស់រដ្ឋ។

ជ-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អនុរដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ចែម ស្ងួន**